## ការធ្វើបទបង្ហាញ និងពិភាក្សាស្តីពីផែនការជម្រើសប្លង់នៃគម្រោងរៀបចំដីធ្លី និងសិទ្ធិមនុស្ស

ប្រជាពលរដ្ឋ ចង់បានការអភិវឌ្ឍណាស់ សំខាន់ឱ្យតែ ការអភិវឌ្ឍដែលអាចឱ្យពួកគាត់អាចទទួលយកបាន។ នេះបើយោងទៅការពិភាក្សាក្រុម ក្រៅផ្លូវការមួយដែលរៀបចំឡើងដោយអង្គការសមាគមជាងត្នោត ក្នុងគម្រោងរៀបចំដីធ្លី និងសិទ្ធិមនុស្ស ដែលមានការចូលរួមពីប្រជាពលរដ្ឋប្រមាណ ១៦០ នាក់មកពីបួនភូមិ នៃសង្កាត់ច្រាំងចំរេះ១ និងសង្កាត់ច្រាំងចំរេះ២ កាលពីខែកញ្ញា និងតុលាកន្លងទៅ។

នៅក្នុងការពិភាក្សានោះបានរកឃើញថា ប្រជាពលរដ្ឋស្ទើរតែទាំងអស់គឺគាត់យល់ព្រមជាមួយរាជរដ្ឋាភិបាល ឬក៏សាលាក្រុងភ្នំពេញប្រសិនបើគេត្រូវការទីតាំងរបស់គាត់ដើម្បីអភិវឌ្ឍ ប៉ុន្តែត្រូវមានដំណោះស្រាយដ៏ល្អមួយដែលពួកគាត់អាចទទួលយកបាន។ តាមរយៈការផ្តល់ជាជម្រើសបី ដែលមានជំរើសទី១ ការអភិវឌ្ឍនៅនឹងកន្លែង ទីពីរការទូទាត់ជាសាច់ប្រាក់ដោយផ្តល់សំណងសមរម្យ និងទីបីការប្តូរជាអគារនៅទីតាំងថ្មី ជាថ្នូរនឹងការអភិវឌ្ឍនៅទីតាំងនេះ បានបង្ហាញថា មានប្រជាពលរដ្ឋ ប្រហែល៨០% ចង់បានការអភិវឌ្ឍនៅនឹងកន្លែង ខណៈពេលដែលអ្នកផ្សេងទៀតបានសម្រេចយកការទូទាត់សំណងដែលមានលក្ខណៈគ្រប់គ្រាន់សម្រាប់ស្វែងរកទីតាំងថ្មី និងការដោះដូរនូវទីតាំងថ្មីមួយដែលស្របទៅនឹងលក្ខខណ្ឌនៃការរស់នៅរបស់ពួកគាត់បាន។ ចំពោះការឆ្លើយតបទៅនឹងមូលហេតុដែលពួកគាត់មិនចង់ចាកចេញ និងចង់បានការអភិវឌ្ឍនៅនឹងកន្លែងនោះដោយពួកគាត់បារម្ភណ៍ថាទីតាំងថ្មីអាចមានលក្ខណៈមិនល្អដូចជាទីតាំងចាស់របស់ពួកគាត់ ដូចជានៅទីតាំងថ្មីពួកគាត់នឹងទទួលបានផ្ទះតូច ទីតាំងថ្មីឆ្ងាយពីកន្លែងធ្វើការ និងមិន មានសេវាសារធារណៈដូចជាវិហារ សាលារៀន មន្ទីរពេទ្យ ឥស្លាមជាដើម។ ម្យ៉ាងទៀតពួកគាត់ពិតជាមានអារម្មណ៍សោកស្តាយព្រោះទីតាំងនេះជាទឹកដីកំណើតដែលពួកគាត់បានរស់នៅតាំងពីយូរយារណាស់មកហើយ។ ក្នុងពេលនោះដែរ បន្ទាប់ពីការធ្វើបទបង្ហាញពីផែនការជម្រើសប្លង់ ដោយក្រុមការងារនៃគម្រោងរៀបចំដីធ្លី និងសិទ្ធិមនុស្ស រួចមកប្រជាពលរដ្ឋដែលបានចូលរួមបានលើកឡើងថា ប្រសិនបើមានការអភិវឌ្ឍនៅនឹងកន្លែងដោយមានការសាង់សង់ជាអគារមាន០៤ជាន់ ពួកគាត់ភាគច្រើនចង់បានជាន់ទី១ច្រើនជាងគេដោយលើកឡើងថាជាន់នេះនឹងផ្តល់លក្ខណៈងាយស្រួលដល់ពួកគាត់ក្នុងការធ្វើអាជីវកម្ម ងាយស្រួលក្នុងការធ្វើដំណើរឡើងចុះ និងលើកឥវ៉ាន់ចេញចូលបានស្រួល។ ក្នុងនោះផងដែរភាគច្រើននៃពួកគាត់ចង់បានលំនៅឋានមួយដែលគាត់អាចបង់រំលោះក្នុងរយៈពេលវែងគឺ១៥ ឆ្នាំក្នុងតម្លៃចន្លោះពី ៥៦-៩៨ ដុល្លា ក្នុងមួយខែ។

កិច្ចបញ្ចប់នៃការពិភាក្សានេះពួកគាត់ភាគច្រើនបានសម្តែងនូវការពេញចិត្តនឹងផែនការជម្រើសប្លង់ដែលក្រុមការងារនៃគម្រោងរៀបចំដីធ្លីបានធ្វើបទបង្ហាញនេះណាស់ តែទោះបីយ៉ាងណាក៏ដោយពួកគាត់ចង់បានលំនៅឋានមួយដែលមានតម្លៃធូរថ្លៃរជាងនេះ និងរយៈពេលវែងជាងការដាក់បង្ហាញនេះ បើអាចសូមអោយលើសពី ១៥ឆ្នាំឡើងទៅ។

សូមបញ្ជាក់ថាផែនការជម្រើសប្លង់ជាផ្នែកមួយនៃគម្រោងរៀបចំដីធ្លី និងសិទ្ធិមនុស្សដែលបានអនុវត្តក្រោមជំនួយឧបត្ថម្ភពីសហគមន៍អ៊ឺរ៉ុប និងទីភ្នាក់ងារអភិវឌ្ឍនៃសាធារណៈរដ្ឋឆេក និងអនុវត្តគម្រោងដោយអង្គការសមាគមជាងត្នោត(STT) និងអង្គការភីបផលអ៊ីននីត(PIN)ដែលមានគោលបំណងផ្សព្វផ្សាយអំពីសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លីទៅដល់ក្រុមប្រជាពលរដ្ឋដែលងាយរងគ្រោះ។

# The Presentation of Spatial Alternative Redevelopment Plan of Human Rights Based Spatial Planning (HRBSP) Project

The people do want development very much, provided that the development could be accepted, according to informal group discussion organized by Samakum Teang Tnaut (STT)'s Human Rights Based Spatial Planning project that participated from about 160 citizens from four villages—village 1,2,3 and Khor in Sangkat Chrang Chamres 1 and Chrang Chamres 2 that we conducted in September and October ago.

In the focus group discussion amongst local people showed that, almost of them agreed with government or municipality of Phnom Penh (MPP)'s plan if they needed this area of Sangkat Chrang Chamres I and II for the development providing that people would be offered with appropriate compensation/ good resolution. In the discussion, three options were highlighted to all people. Through the three options (i.e 1) an on-site redevelopment plan. 2) Compensation and 3) Relocation site development. The result indicated that, around 80% of them accepted with an on-site redevelopment plan, while others decided to ask for appropriate compensation and the last option was relocation site development with good standard of living. In relation to the reasons why they didn't want to leave from this area or wanted an on-site redevelopment plan, the answers were that they worried with the new location if the new one will be worse than their old site or acceptable location. It meant that, they will be offered with small houses, small size of land, further from their work site, no public services, no mosque to pray, no Islam school or what else. On the other hand, another reason was that, they would have missed the location where they used to settle down because it was their ancestors' land.. After they listened carefully to the presentation of the staff of HRPSP project group about redevelopment plan, the participants expressed that if that project would come true with four storey buildings like the presentation they would prefer choosingthe first floor the most because this floor would be easy/favorable for them to run their home businesses, then it would be easy to climb up and down to carry materials.. Moreover, the apartment that people could pay installment for a 15 years period and the price between 56$ to 98$ per month would be the most popular choice for the participants.

At the end of the discussion, most participants were really enjoy with this redevelopment plan which was presented by HRPSP group. However, they suggested that they wanted the low price housing and paid installment with long time than 15 years, if it's possible they like paying installment with more than 15 years.

Be informed that, spatial alternative redevelopment plan is the part of Human Rights Based Spatial Planning Project in Cambodia which is funded by European Union and Czech Development Agency and implemented by Sahmakum Teang Tnaut (STT) and People in Need (PIN) organization for the promotion of tenure security for the most vulnerable and marginalized groups in Cambodia.

A- Tentative Architectural Plan



B- Maste plan



C- Staff of HRBSP project of STT were providing explanation about spatial alternative redevelopment plan to local people in village 1.







